# ទណ្ឌកម្មរបស់សហរដ្ឋអាមេរិក
# និងការប្រកួតប្រជែងឥទ្ធិពលរវាង ចិន-អាមេរិក នៅអាស៊ីអាគ្នេយ៍

ដោយ៖ លោក អ៊ុច លាង អ្នកសិក្សាស្រាវជ្រាវនៃនាយកដ្ឋានសិក្សាអាស៊ី អាហ្វ្រិក និងមជ្ឈិមបូព៌ា
នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា នៃរាជបណ្ឌិត្យសភាកម្ពុជា

*គិតរហូតមកទល់ពេលនេះ ក្នុងបរិបទនៃការប្រកួតប្រជែងឥទ្ធិពល រវាងសហរដ្ឋអេម៉េរិក និងចិន ដែលកំពុងតែមានភាពក្ដៅគគុកនៅ តំបន់អាស៊ីអាគ្នេយ៍ មានបុគ្គល ក្រុមហ៊ុន និងប្រទេសមួយចំនួន កំពុងជាប់ និងត្រៀមនឹងជាប់ទណ្ឌកម្មសេដ្ឋកិច្ច របស់សហរដ្ឋអាម៉េរិក នៅក្រោមហេតុផលថាស្ដារប្រជាធិបតេយ្យ និងកែលម្អលក្ខខណ្ឌសិទ្ធិមនុស្ស។ ការដាក់ទណ្ឌកម្មនេះ គឺជាផ្នែកមួយដ៏សំខាន់ ក្នុងការបង្កើនប្រសិទ្ធភាពនៃនយោបាយការបរទេស របស់អាម៉េរិក ប៉ុន្តែទន្ទឹមនឹងគ្នានេះដែរ វាក៏បានបង្ក ឱ្យមានផលប៉ះពាល់យ៉ាងច្រើន ដល់សេដ្ឋកិច្ច របស់បណ្ដាប្រទេសពាក់ព័ន្ធ ទាំងនោះផងដែរ។ នយោបាយដាក់ទណ្ឌកម្ម ជាធម្មតា ត្រូវបានអនុវត្តទៅលើបុគ្គល ក្រុមហ៊ុន ឬប្រទេសណា ដែលអាម៉េរិកចាត់ទុកថា បានបំផ្លាញនូវគុណតម្លៃប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។*

*សូមរំលឹកថា ទិវាអន្តរជាតិប្រឆាំងនឹងអំពើពុករលួយដែលបានប្រារព្ធធ្វើឡើង នៅរាល់ឆ្នាំ នៅថ្ងៃទី៩ ខែធ្នូ នេះ គឺចាប់ផ្ដើមធ្វើឡើង តាំងពីមហាសន្និបាតនៃអង្គការសហប្រជាជាតិ បានអនុម័តលើអនុសញ្ញានៃអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ (UNCAC) កាល ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ មកម្ល៉េះ។ ដែលពេលនោះ មានភាគីរដ្ឋចំនួន១៨៧ ចូលរួម នៅក្នុងអនុសញ្ញានេះ។ នៅក្នុងទិវាអន្តរជាតិប្រឆាំងនឹងអំពើពុករលួយ នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២០ កន្លងទៅ ការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិបរទេស (OFAC) នៃក្រសួងរតនាគាររបស់សហរដ្ឋអាម៉េរិក បានដៅទៅលើបុគ្គលប្រព្រឹត្ត អំពើពុករលួយ និងបណ្ដាញរបស់គេ នៅក្នុងប្រទេសជាច្រើន នៅទ្វីបអាហ្វ្រិក និងទ្វីបអាស៊ី ដោយអនុលោមតាម ច្បាប់ស្ដីពីគណនេយ្យភាពផ្នែកសិទ្ធិមនុស្ស Global Magnitski Act។*

*ជាលទ្ធផលនៃចំណាត់ការនៃការដាក់ទណ្ឌកម្មគឺ ទ្រព្យសម្បត្តិ និងផលប្រយោជន៍ទាំងអស់របស់អ្នក ដែលត្រូវបានជាប់ទណ្ឌកម្ម ដែលមាននៅក្នុងសហរដ្ឋអាម៉េរិក ស្ថិតនៅក្នុងដៃ*

ឬគ្រប់គ្រង ដោយស្ថាប័នអាម៉េរិក ត្រូវបានបង្កក ហើយត្រូវបានជូនដំណឹងទៅ OFAC។ ក្រៅពីនេះទៀត អ្វីដែលជាកម្មសិទ្ធិ ដោយផ្ទាល់ឬដោយប្រយោល ក្នុងចំនួនចាប់ពី ៥០%ទៅរបស់ក្រុមមួយឬច្រើន ដែលត្រូវបានបង្កក ក៏រងការបង្កកផងដែរ។ បើគ្មានការអនុញ្ញាតដោយអាជ្ញាប័ណ្ណ ទូទៅឬពិសេសណាមួយដែលចេញដោយ OFAC ឬត្រូវបានលើកលែងក្នុង រូបភាពណាមួយនោះ បទបញ្ញារបស់ OFAC ជាទូទៅ នឹងហាមទៅលើការប្រតិបត្តិការទាំងអស់ដោយក្រុម ដែលស្ថិតនៅក្នុងសហរដ្ឋអាម៉េរិក ឬនៅក្នុងវង្វង់ប្រទេសអាម៉េរិក ដែលមានការពាក់ព័ន្ធនឹង ទ្រព្យសម្បត្តិ ឬផលប្រយោជន៍ក្នុងទ្រព្យសម្បត្តិរបស់ក្រុមដែលរងការបង្កក។ ការហាមប្រាមរួមមានការរួមចំណែកឬការផ្តល់ជាប្រាក់ ទំនិញឬសេវា ដល់ឬសម្រាប់ ជាប្រយោជន៍ដល់ក្រុមដែលរងការបង្កក ឬការទទួលនៃការរួមចំណែកឬការផ្តល់ថវិកា ទំនិញ ឬសេវាពីក្រុមនោះ។

យោងតាមសេចក្តីប្រកាសព័ត៌មាន នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២០ ដែលបានចុះផ្សាយនៅលើគេហទំព័ររបស់ ស្ថានទូតសហរដ្ឋអាម៉េរិកនៅកម្ពុជា ដែលមានចំណងជើងថា ***ទណ្ឌកម្មរបស់ក្រសួងរតនាគារប្រឆាំងនឹងបុគ្គលពុករលួយ នៅអាហ្វ្រិក និងអាស៊ី*** បានឱ្យដឹងថា៖ លោក Wan Kuok Koi ដែលគេច្រើនហៅថា Broken Tooth (ធ្មេញបាក់) គឺជាសមាជិកម្នាក់នៃសន្និសីទពិគ្រោះយោបល់នយោបាយរបស់ប្រជាជនចិន នៃគណបក្សកុម្មុនិស្តចិន (CCP) ហើយដឹកនាំក្រុម 14K ដែលជាក្រុមមួយក្នុងចំណោមក្រុមសម្ងាត់ធំៗ ដែលមានការចាត់តាំងរបស់ចិន នៅក្នុងពិភពលោក ហើយដែលធ្វើសកម្មភាពជួញដូរគ្រឿងញៀន បើកល្បែងស៊ីសងខុសច្បាប់ ធ្វើជំនួញខុសច្បាប់ ប្រព្រឹត្តការជួញដូរមនុស្ស និងសកម្មភាពខុសច្បាប់ដទៃជាច្រើនទៀត។ ក្រុម 14K ក្រៅពីធ្វើការសូកប៉ាន់ និងប្រព្រឹត្តអំពើពុករលួយ បានប្រព្រឹត្តសកម្មភាពខុសច្បាប់បែបនេះ នៅ Palau ។

Broken Tooth ត្រូវបានចាត់ទុកថាជាជនបរទេស ជាមេដឹកនាំឬជាមន្ត្រីនៃអង្គការស្ថាប័នមួយ ដែលរួមទាំងជាអង្គការស្ថាប័នរដ្ឋាភិបាល ដែលបានចូលរួម ឬដែលមានសមាជិកបានចូលរួមក្នុងអំពើពុករលួយ ដូចជាការកែបន្ទំយកទ្រព្យសម្បត្តិរដ្ឋ ដកហូតយកទ្រព្យសម្បត្តិឯកជនសម្រាប់ខ្លួនឯង អំពើពុករលួយទាក់ទងនឹងកុងត្រារបស់រដ្ឋាភិបាល ឬការធ្វើអាជីវកម្មលើធនធានធម្មជាតិ ឬការសូកប៉ាន់។

OFAC ថែមទាំងបានធ្វើការដៅទៅលើអង្គការ/ស្ថាប័នចំនួន ៣ ដែលមាន Broken Tooth ជាម្ចាស់ ឬគ្រប់គ្រងដោយ Broken Tooth៖ ទី១-សមាគម World Hongmen History and Culture Association ដែលមាន មូលដ្ឋាននៅកម្ពុជា ហើយត្រូវបានបង្កើតឡើងដោយ Broken Tooth នៅឆ្នាំ ២០១៨។ ទី២- Dongmei Group ដែលមានមូលដ្ឋាននៅហុងកុង និង ទី៣- សមាគម Palau China Hung-Mun Cultural Association មានមូលដ្ឋាននៅ Palau

នៅឆ្នាំ២០១៨ Broken Tooth បានបង្កើតទីស្នាក់ការកណ្តាលរបស់សមាគម World Hongmen History and Culture Association នៅកម្ពុជា។ Hongmen (ឬ Hung Mun) គឺជាអង្គការសាកលរបស់បងប្អូនចិន ដែលត្រូវបានបង្កើតឡើងនៅពាក់កណ្តាលទសវត្សរ៍ ១៦០០ ហើយមានលក្ខណៈដូច "ក្រុមសង្គមងងឹត" នៅហុងកុង និងម៉ាកាវ។ ក្រុមសង្គមងងឹត 14K កំពុងតែប្រើសមាគម World Hongmen History and Culture Association របស់ Broken Tooth ដើម្បីធ្វើឱ្យខ្លួនមានភាពស្របច្បាប់។

នៅក្រោមការដឹកនាំរបស់ Broken Tooth សមាគម World Hongmen History and Culture Association បានជ្រើសរើសបាននូវសមាជិកសំខាន់ៗ នៅប្រទេសម៉ាឡេស៊ី និងប្រទេសកម្ពុជា។ ការបង្កើតសមាគម World Hongmen History and Culture Association នេះដោយ Koi បន្តបែបផែននៃក្រុមរបស់ប្រទេសចិន ដែលខិតខំលាក់បាំងសកម្មភាពល្មើសច្បាប់ ដោយបង្ហាញសកម្មភាពរបស់គេថាស្ថិតនៅក្នុងក្របខ័ណ្ឌនៃគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់មួយ ផ្លូវមួយរបស់ប្រទេសចិន (BRI) សុបិនចិន(Chinese Dream) ឬគំនិតផ្តួចផ្តើមសំខាន់ៗដទៃទៀត របស់គណបក្សកុម្មុយនិស្តចិន។ សមាគម World Hongmen History and Culture Association កំពុងរីកធំនៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ ដោយបង្កើតជាបណ្តាញរកស៊ីដ៏មានឥទ្ធិពល ដែលមានការពាក់ព័ន្ធនឹងការបង្កើត និងចេញរូបិយវត្ថុ crypto អចលនទ្រព្យ ហើយក្នុងពេលថ្មីៗនេះ បង្កើតក្រុមហ៊ុនសន្តិសុខ ដែលមានជំនាញខាងការពារវិនិយោគ BRI ។

សហគ្រាសរបស់ចិន ដែលនៅពីក្រោយគម្រោង BRI មានលក្ខណៈដូចគ្នាជាច្រើន ពោលគឺថា វាមានអ្នកដឹកនាំដែលមានការទាក់ទងជាមួយនឹងបណ្តាញឧក្រិដ្ឋជន ឬក្រុមដែលមានការពាក់ព័ន្ធនឹងសកម្មភាពខុសច្បាប់ នៅកន្លែងដទៃទៀតនៅអាស៊ីអាគ្នេយ៍ ព្រមទាំងនៅប្រទេសចិន។ សហគ្រាសទាំងនោះមានអង្គការរបស់វាជាស្រេច ដែលមានបើកកាស៊ីណូ និង

ចេញលុយ Crypto ។ គេប្រកាសខ្លួនគេនៅតាមអ៊ិនធឺណិតថា មានទាក់ទងនឹងគម្រោង BRI របស់ប្រទេសចិន ហើយបានអួតពីការទាក់ទងជាមួយនឹងទីភ្នាក់ងារសំខាន់ៗនៃរដ្ឋាភិបាលចិន ហើយសហគ្រាសទាំងអស់នោះ បានបង្កើតសមាគមដែលធ្វើសកម្មភាពជួយដល់ជនជាតិចិន។

ក្រៅពីជួយជំរុញដល់គម្រោង BRI របស់គណបក្សកុម្មុយនិស្តចិន តាមរយៈសមាគម World Hongmen History and Culture Association, Broken Tooth ថែមទាំងដឹកនាំក្រុម Dongmei Group ថែមទៀតផង។ ក្រុមនេះគឺជាវិនិយោគិនសំខាន់នៅតំបន់ Saixigang Zone នៃប្រទេសភូមា។

ដោយឡែក កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ គណៈកម្មាធិការទំនាក់ទំនងការបរទេសព្រឹទ្ធសភា អាម៉េរិក បានអនុម័តច្បាប់ ដើម្បីដាក់ទណ្ឌកម្មបុគ្គល និងស្ថាប័នចិនដែលពាក់ព័ន្ធ នឹង ជម្លោះនៅសមុទ្រចិនខាងត្បូង និងខាងកើត។ ហើយបើយោង សេចក្ដីប្រកាសរបស់ SRFC ចុះថ្ងៃទី១៩ ខែ១០ នៅលើបណ្ដាញសង្គម Twitter បានលើកឡើងថា "នៅក្នុងកិច្ចប្រជុំនោះ គណៈកម្មាធិការទំនាក់ទំនងការបរទេសព្រឹទ្ធសភា (SFRC)បានអនុម័តច្បាប់ ស្ដីពីការដាក់ ទណ្ឌកម្មនៅសមុទ្រចិនខាងត្បូង និងសមុទ្រចិនខាងកើតឆ្នាំ២០២១។ ច្បាប់នេះត្រូវបានអនុម័ត ដោយ(SFRC) ក្នុងបំណងដាក់ទណ្ឌកម្មលើបុគ្គល និងស្ថាប័ន្ឋ ចិនដែលចូលរួមក្នុងសកម្មភាព ទាក់ទងនឹងជម្លោះនៅសមុទ្រចិនខាងត្បូង និងខាងត្បូង។ បន្ទាប់ពីត្រូវបានអនុម័តនៅ SRFC ច្បាប់នេះនឹងត្រូវពិភាក្សានិងបោះឆ្នោតនៅព្រឹទ្ធសភាអាម៉េរិក។ នៅក្នុងសេចក្ដីថ្លែងការណ៍នាថ្ងៃ ទី១៩ ខែតុលា របស់សមាជិកព្រឹទ្ធសភា Rubio និង Cardin បានស្វាគមន៍ការអនុម័ត ច្បាប់នេះដោយ(SFRC)។

តាមការលើកឡើងរបស់លោក Rubio សមាជិកជាន់ខ្ពស់នៃគណៈកម្មាធិការទំនាក់ទំនងការបរទេសព្រឹទ្ធសភា បានឱ្យដឹងថា "គ្មានការគំរាមកំហែងធំជាងមុនចំពោះតំបន់ ឥណ្ឌូប៉ាស៊ីហ្វិកសេរី និងបើក ចំហជាងចិននិងកងកម្លាំងប្រដាប់អាវុធទេ។ ទឹកដីនៅសមុទ្រចិនខាងកើតនិងខាងត្បូង" ។ លោក Rubio បានហៅការអនុម័តច្បាប់របស់គណៈកម្មាធិការ នេះថាជាជំហានដំបូង ដ៏សំខាន់ ហើយលោកបានអំពាវនាវឱ្យព្រឹទ្ធសភា ទាំងមូលអនុម័តសេចក្ដីព្រាងច្បាប់នេះឱ្យបានឆាប់រហ័ស។ ជាមួយគ្នានេះសមាជិកព្រឹទ្ធសភា Cardin បានលើកឡងថា

"អាកប្បកិរិយាឈ្លានពានរបស់ចិន ទាំងនៅសមុទ្រចិនខាងត្បូង និងខាងកើត ត្រូវតែគ្រប់គ្រង"។ "ច្បាប់របស់យើង ជាការផ្ញើសារ ថា សហរដ្ឋអាម៉េរិក នឹងការពារលំហូរពាណិជ្ជកម្មដោយសេរី និងសេរីភាព នាវាចរណ៍ការពារ អធិបតេយ្យភាពរបស់សម្ព័ន្ធមិត្តរបស់យើង និងលើកកម្ពស់ដំណោះស្រាយការទូតដោយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ"។ ប្រសិនបើអនុម័តជាផ្លូវការ ច្បាប់ស្តីពីទណ្ឌកម្មលើ តំបន់សមុទ្រចិន ខាងត្បូង និងសមុទ្រចិនខាងកើត នឹងអនុញ្ញាតឱ្យរដ្ឋាភិបាលអាម៉េរិក រឹបអូសទ្រព្យសម្បត្តិ ហិរញ្ញវត្ថុនៅអាម៉េរិក ដកហូតឬលុបចោលទិដ្ឋាការអាម៉េរិក សម្រាប់ជនជាប់ចោទណា ដែលពាក់ព័ន្ធនឹងសកម្មភាព ឬគោលនយោបាយដែលគំរាមកំហែង ដល់សន្តិភាពសន្តិសុខ និងស្ថិរភាព" នៅសមុទ្រចិនខាងត្បូង និងខាងកើត។

ច្បាប់ថ្មីនេះ ក៏តម្រូវឱ្យរដ្ឋលេខាធិការបញ្ជូនរបាយការណ៍ទៅសភារៀងរាល់ ៦ខែម្តង ដើម្បីកំណត់អត្តសញ្ញាណបុគ្គលឬក្រុមហ៊ុនចិន ដែលពាក់ព័ន្ធនឹងការសាងសង់ឬការអភិវឌ្ឍន៍គម្រោងខុសច្បាប់ ដែលគ្មានការអនុញ្ញាត នៅសមុទ្រចិនខាងត្បូង។ សកម្មភាពខុសច្បាប់ដែលគ្របដណ្តប់ដោយច្បាប់ អាម៉េរិករួមមាន ការរុះរើសំណង់កោះសិប្បនិម្មិត ការសាងសង់បង្គោលភ្លើងហ្វារនិងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ចល័ត។ បុគ្គលឬស្ថាប័ន្ត ដែលមានការចូលរួមដោយផ្ទាល់នៅក្នុងសកម្មភាពដែលគំរាមកំហែងដល់ "សន្តិភាពសន្តិសុខឬស្ថិរភាព" នៅក្នុងតំបន់ដែលគ្រប់គ្រង ដោយជប៉ុនឬកូរ៉េខាងត្បូង នៅសមុទ្រចិនខាងកើត ក៏ត្រូវបាន ដាក់គោលដៅដាក់ទណ្ឌកម្មក្រោមច្បាប់ថ្មីនេះដែរ។ សូមបញ្ជាក់ថា នៅសមុទ្រចិនខាងកើត ជប៉ុន និងចិន មានជម្លោះជុំវិញប្រជុំកោះសេនកាគូ (ដែលចិនហៅថា ដាយយូ)។

សូមរំលឹកផងដែរថា ច្បាប់ស្តីពីការដាក់ទណ្ឌកម្មនៅសមុទ្រចិនខាងត្បូង និងខាងកើតនេះ ធ្លាប់បានដាក់ស្នើទៅព្រឹទ្ធសភាជាលើកដំបូង ក្នុងខែឧសភា ឆ្នាំ២០១៩ រួចម្តងទៅហើយ ហើយក៏បានដាក់ស្នើជាថ្មីម្តងទៀតនៅក្នុងខែឧសភា ឆ្នាំ២០២១នេះ។

ជាសរុបមក យើងសង្កេតឃើញថា ការព្យាយាមដាក់ចេញនូវច្បាប់ ស្តីពីការដាក់ទណ្ឌកម្មទៅលើ បុគ្គ ស្ថាប័នពាក់ព័ន្ធ ដែលជាទូទៅយើងមើលឃើញថា មកពីប្រទេសចិន ដែលពាក់ព័ន្ធនិងគម្រោង BRI របស់ចិន ដែលកំពុងប្រកួតប្រជែងជាមួយ Free and Open Indo-Pasific របស់សហរដ្ឋអាម៉េរិក និងការប្រកួតដែងឥទ្ធិពលនៅតំបន់សមុទ្រចិនខាងត្បូង និង

ខាងកើត ដែលកំពុងតែមានភាពតានតឹងដាក់គ្នា គឺជាការព្យាយាមស្វែងរក និងរក្សាឱ្យបាននូវតុល្យភាពនៃអំណាច និងឥទ្ធិពល របស់ប្រទេសមហាអំណាច ជាពិសេសសហរដ្ឋអាម៉េរិក នៅក្នុងតំបន់អាស៊ី ជាពិសេសអាស៊ីអាគ្នេយ៍ ដែលត្រូវបានសហគមន៍អន្តរជាតិ មើលឃើញថាកំពុងតែត្រូវបានគ្របដណ្ដប់ដោយការរះឡើង យ៉ាងឆាប់រហ័ស របស់ប្រទេសចិន ក្រោយពីមិនសូវបានអើពើ នៅអំឡុងដើម និងពាក់កណ្ដាលអាណត្តិ របស់លោកប្រធានាធិបតីត្រាំ ហើយបានជះឥទ្ធិពលមកលើប្រទេសមួយចំនួនក្នុងតំបន់ ដែលមានទំនាក់ទំនងជាមួយបុគ្គលឬសហគ្រាស ដែលត្រូវបានដាក់ទណ្ឌកម្មដោយសហរដ្ឋអាម៉េរិក៕